ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ:៨៦
ចុះថ្ងៃទី១៨-០២-២០០៨
សាលដីកា
លេខ: ៩៨ញ
ចុះថ្ងៃទី០៧-១០-២០០៩

# តាងនាមប្រជារាស្ត្រខ្មែរ
# សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍

ឆ្នាំពីរពាន់ប្រាំបួន ខែតុលា ថ្ងៃទីប្រាំពីរ វេលាម៉ោងប្រាំបីព្រឹក បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ ដែលមានសមាសភាពដូចតទៅ:

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted] ជាព្រះរាជអាជ្ញា

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:៨៦ ចុះថ្ងៃទី១៨-០២-២០០៨រវាង:

**-<u>ជនជាប់ចោទ:</u>**

១-ឈ្មោះ: [redacted] **ស៊ីថា** ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ [redacted] ចាប់ខ្លួនថ្ងៃទី១៩-០៦-២០០៧, ឃុំខ្លួនថ្ងៃទី២៥-០៦-២០០៧ (ព្រៃស) ។

២-ឈ្មោះ: [redacted] **សុមិន** ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ [redacted] ចាប់ខ្លួនថ្ងៃទី១៩-០៦-២០០៧, ឃុំខ្លួនថ្ងៃទី២៥-០៦-២០០៧ (ព្រៃស) ។

៣-ឈ្មោះ: [redacted] **សុមុន** ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ [redacted] ចាប់ខ្លួននៅថ្ងៃទី១៩-៦-២០០៧, ឃុំខ្លួននៅថ្ងៃទី២៥-៦-២០០៧ (ព្រៃស) ។

-មេធាវីការពារជនជាប់ចោទ [redacted] **ម៉ិច** ។

<u>ត្រូវចោទពីបទ:</u> ប្លន់(លួចច្រើនគ្នា) កាលពីថ្ងៃទី៣១-០៥-២០០៧ នៅក្រុងភ្នំពេញ។ បទល្មើស មានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦ ច្បាប់ស្តានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-និងដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ: [redacted] ភេទប្រុស អាយុ៤២ឆ្នាំ មានទីលំនៅផ្ទះលេខ: [redacted] ។/.

## ឯរឿងហេតុដូចតទៅ :

-កាលពីថ្ងៃទី ៣១-០៥-២០០៧ និងថ្ងៃទី ១៥-០៦-២០០៧ នៅចំណុចក្នុងក្រុមហ៊ុនឆាយណា យូណាន់ ក្រុងភ្នំពេញ ជនល្មើសឈ្មោះ [redacted] ស៊ីថា, [redacted] សុបិន, [redacted] សុបុន បានធ្វើសកម្មភាពលួចយកដែក និងខ្សែភ្លើងរបស់ក្រុមហ៊ុន ។ ពេលលួចបាន ជនល្មើសទាំងបីនាក់ខាងលើយកទៅលក់ចែកគ្នា លុះដល់ថ្ងៃទី ១៥-០៦-២០០៧ ក៏ត្រូវបានសមត្ថកិច្ច សន្តិសុខក្រុមហ៊ុនធ្វើការឃាត់ខ្លួនបញ្ជូនមកសមត្ថកិច្ចតែម្តង ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៥ កបIII ចុះថ្ងៃទី ០៥-១២-២០០៧ របស់សាលាដំបូងក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេច ដូចតទៅ :

១-ផ្តន្ទាទោស :

-ឈ្មោះ [redacted] ស៊ីថា ភេទប្រុស អាយុ ២១ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ២៥-០៦-២០០៧ ពីបទ : ប្លន់ (លួចដែកមានគ្នាច្រើន) ប្រព្រឹត្តនៅសង្កាត់អូរបែស្សីទី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ អំឡុងដើមខែឧសភា ឆ្នាំ ២០០៧, ៣១-០៥-២០០៧ និងថ្ងៃទី ១៥-០៥-២០០៧ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ឈ្មោះ [redacted] សុបិន ភេទប្រុស អាយុ ៣៣ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ២៥-០៦-២០០៧ ពីបទ : ប្លន់ (លួចដែកមានគ្នាច្រើន) ប្រព្រឹត្តនៅសង្កាត់អូរបែស្សីទី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ អំឡុងដើមខែឧសភា ឆ្នាំ ២០០៧, ៣១-០៥-២០០៧ និងថ្ងៃទី ១៥-០៥-២០០៧ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ឈ្មោះ [redacted] សុបុន ភេទប្រុស អាយុ ៤២ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៥ ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ២៥-០៦-២០០៧ ពីបទ : ប្លន់ (លួចដែកមានគ្នាច្រើន) ប្រព្រឹត្តនៅសង្កាត់អូរបែស្សីទី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១-០៥-២០០៧ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-បង្គាប់ឱ្យឈ្មោះ [redacted] ស៊ីថា, [redacted] សុបិន និង [redacted] សុបុន រួមគ្នាសងបំណងជួសជុលការខូចខាត និងជម្ងឺចិត្តសរុប ២.០០០.០០០ រៀល អោយទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ។ ក្នុងករណីរឹងរូស ពុំព្រមសងសំណង ត្រូវដាក់គុកបង្ខំរូបកាយ តាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។ សំណូមពរលើសពីនេះបដិសេធចោល ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១០-០១-២០០៨ របស់ឈ្មោះ [redacted] ស៊ីថា និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៤-១២-២០០៧ របស់ឈ្មោះ ចាន់ សុបិន និង ចាន់ សុបុន ។

-បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី.............................របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។ /V.

## នារពេលសទនាការ

-ដើមបណ្តឹងឈ្មោះ [redacted] ( មិនចូល)

-ជនជាប់ចោទ [redacted] ស៊ីថា ( ចូល)

-ជនជាប់ចោទ [redacted] សុបិន ( ចូល)

-ជនជាប់ចោទ [redacted] សុបុន ( ចូល)

-មេធាវីការពារជនជាប់ចោទ [redacted] ម៉ាច (ចូល)

## ប្រធានក្រុមប្រឹក្សាសទ្ទួបអង្គហេតុ

-ជនជាប់ចោទឈ្មោះ [redacted] សុបិន ឆ្លើយថា : ខ្លួនឃើញគេបោះដែកចេញមក ខ្លួនក៏រើសទុក ឃើញ [redacted] ស៊ីថា ចេញមក ខ្លួនក៏សួរ គេមិនឆ្លើយទេ បែរជានិយាយថា រឿងគេស្រេចតែគេ ក្រោយពីលក់បានលុយ គេក៏ឱ្យមកខ្លួនមួយម៉ឺនរៀល ។

-ជនជាប់ចោទឈ្មោះ [redacted] ស៊ីថា ឆ្លើយថា : ខ្លួនជាអ្នកបោះដែកចេញមកក្រៅមែន ហើយគេទាំងពីរនាក់រើសមែន តាពិតគេទាំងពីរនាក់មិនដឹងអីមែន ។ ចំពោះខ្សែភ្លើង ខ្លួនលួចតែម្នាក់ឯងទេ ពុំមានពាក់ព័ន្ធនឹងអ្នកទាំងពីរនេះដែរ ។ កន្ទុយដែកខ្វី១ ខ្លួនជាអ្នកយកទៅលក់ ខ្សែភ្លើងខ្លួនយកតែម្នាក់ឯងចំនួន ៣ ម៉ែត្រប៉ុណ្ណោះ ។

-ជនល្មើសទាំងបីសុំអោយក្រុមប្រឹក្សាបន្ធូរបន្ថយទោស ។

## តំណាងមហាអយ្យការសន្និដ្ឋាន

ជនល្មើសទាំងបីបានសារភាពអស់ហើយ១សុំឱ្យក្រុមប្រឹក្សាបន្ធូរបន្ថយទោស ដូច្នេះ សុំក្រុមប្រឹក្សាសំរេចតាមច្បាប់ ។

## ក្រុមប្រឹក្សាជំនុំជម្រះថយពិភាក្សា និងប្រកាសសាលដីកា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១០-០១-២០០៨ របស់ឈ្មោះ [redacted] ស៊ីថា និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៤-១២-២០០៧ របស់ឈ្មោះ [redacted] សុបិន និង [redacted] សុបុន ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទបានឆ្លើយសារភាពថា ពួកខ្លួនទាំងបីនាក់ពិតជាបានលួចយកកំណាត់ដែកក្រុមហ៊ុនទៅលក់ពិតប្រាកដមែន ឃើញថាមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ស៊ីថា. [redacted] សុបិន. ចាន់ សុបុន ពីបទ : ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ៣១-០៥-២០០៧ និងថ្ងៃទី ១៥-០៦-២០០៧ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៣-អំពើរបស់ជនជាប់ចោទខាងលើជាអំពើប្លន់ ( លួចគ្នាច្រើន) មែនពិត តែព្យសនកម្មនៃអំពើតូចតាច និងអំពើរបស់ជនជាប់ចោទពុំបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សង្គម ដូចនេះ គប្បីក្រុមប្រឹក្សា /ᵂ.

ពិចារណាលើចំណុចអប្បរមានៃទោសដល់ជនជាប់ចោទ ហើយម្យ៉ាងទៀត ជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ។

៤-រឿងក្តីនេះត្រូវបានសាលាដំបូងក្រុងភ្នំពេញ ធ្វើការអង្កេតនិងលើកសំអាងហេតុ មកបញ្ជាក់ត្រឹមត្រូវហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដូចនេះសាលាឧទ្ធរណ៍ពុំចាំបាច់លើកយកសំអាងហេតុដដែលនោះមកបញ្ជាក់សាជាថ្មីទៀតទេ ។

៥-សាលក្រមព្រហ្មទណ្ឌលេខ: ១៥៤កបឃ ចុះថ្ងៃទី០៥-១២-២០០៧ របស់សាលាដំបូងក្រុងភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ លើកលែងតែចំណុចដូចបានលើកឡើងខាងលើ គប្បីត្រូវកែប្រែ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១០-០១-២០០៨ របស់ឈ្មោះ [redacted] ស៊ីថា និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤-១២-២០០៧ របស់ឈ្មោះ [redacted] សុបិន និង [redacted] សុបុន ទុកជាត្រឹមត្រូវតាមច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ១៥៤កបឃ ចុះថ្ងៃទី០៥-១២-២០០៧ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំណុចទី១ ត្រង់ចំណុច "ផ្តន្ទាទោសឈ្មោះ [redacted] ស៊ីថា និង ចាន់ សុបិន ដាក់ពន្ធនាគារកំណត់៥ឆ្នាំវិញ" ចំណុចក្រៅពីនេះ រក្សាទុកជាបានការដដែល ។

៣-បន្តការឃុំខ្លួនលើជនជាប់ចោទ។

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី០៧-៩-២០០៩ ចំពោះមុខជនជាប់ចោទ , មេធាវីការពារឲ្យជនជាប់ចោទ កំបាំងមុខដើមបណ្តឹង បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

"ត្រូវបានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ភ្នំពេញ, ថ្ងៃទី ២៤ ខែ ១២ ឆ្នាំ២០១៤
**ក្រឡាបញ្ជី**
[redacted]

បានឃើញ
**ប្រធានសាលាឧទ្ធរណ៍**
[redacted]